# បងប្រុសរបស់អ្នកទោសរស់រានមានជីវិតពីមន្ទីរស-២១ ត្រូវបានបង្ខំឱ្យសម្លាប់ឪពុករបស់ខ្លួន មុននឹងត្រូវគេសម្លាប់ដោយសារតែគាត់ស្ទាក់ស្ទើរនឹងការធ្វើតាមបញ្ជា

*ដោយ ឡូរ៉ា ម៉ាកដូណល់*

*ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

ថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូង បានស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាស្ត្រីពីររូបដែលបានអះអាងថា ត្រូវបានជាប់ឃុំឃាំងនៅគុកទួលស្លែង (មន្ទីរស-២១) នៅទីក្រុងភ្នំពេញ មុននឹងត្រូវបញ្ជូនទៅកាន់កន្លែងកសាងខ្លួនព្រៃស (មន្ទីរស-២៤) ។ ស្ថិតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មន្ទីរឃុំឃាំងទាំងអស់នេះ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។

## រូបថតពាក់កណ្តាលខ្លួនរបស់ ជិន ម៉េត បានដាក់តាំងបង្ហាញនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ប៉ុន្តែតើរូបថតនេះមានប្រភពមកពីណា?

ក្រោយពីការចោទសួរសំណួរពីសំណាក់ចៅក្រមកាលពីម្សិលមិញមក ដើមបណ្តឹងរដ្ឋប្បវេណី ជិន ម៉េត អាយុ៥១ឆ្នាំ បានវិលចូលមកបង្ហាញខ្លួនម្តងទៀតនៅក្នុងថ្ងៃនេះ ។ មុននឹង ជិន ម៉េត ចាប់ផ្តើមផ្តើសក្ខីកម្ម ព្រះរាជអាជ្ញាបានព្យាយាមដាក់ចំពោះអង្គជំនុំជម្រះនូវរូបថតរបស់ ជិន ម៉េត ដែលគាត់បានភ្ជាប់មកជាមួយតាំងពីម្សិលមិញ ។ ក្នុងរយៈពេលសែសិបនាទីនៃការពិភាក្សា និងការបង្ហាញរូបថតពេញក្នុងបន្ទប់សវនាការមក ចៅក្រមបានទទួលស្គាល់រូបថតពាក់កណ្តាលខ្លួនរបស់ ជិន ម៉េត និងរូបថតនារីពីររូបទៀត ដែលបានដាក់បង្ហាញនៅក្នុងកន្លែងតាំងរូបថតរបស់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ បញ្ហានីតិវិធីដ៏តូចនេះបានកើតឡើង ដោយសារតែវាគឺជាបញ្ហាសារធាតុសំខាន់មួយ ។ មេធាវីរបស់ ជិន ម៉េត និងមេធាវីការពារក្តីបានជំទាស់គ្នាអំពីកន្លែងដែល ជិន ម៉េត ថតរូប និងពីភស្តុតាងដែលអាចបញ្ជាក់បានពីការអះអាងនោះ ។ មេធាវីការពារក្តីអះអាងថា ជិន ម៉េត បាននិយាយថា រូបថតនេះត្រូវបានថតនៅមន្ទីរស-២៤ ។ ប៉ុន្តែមេធាវីរបស់ ជិន ម៉េត បានជំទាស់ថាការពិតមិនទាន់បានបញ្ជាក់ឲ្យច្បាស់នៅឡើយទេ ។ បន្ថែមលើនេះ លោកមេធាវីបានរៀបរាប់ថា កាល

ពីម្សិលមិញ ឌុច និយាយថា រូបថតនេះមានប្រភពចេញពីមន្ទីរស-២៤ ប៉ុន្តែ ជិន ម៉េត ទេដែលនិយាយថា រូបថតនេះថតនៅកងពលទ័ពដែលគាត់បានបំរើការមុននឹងត្រូវបានចាប់ខ្លួនបញ្ជូនមកកាន់មន្ទីរស-២១ និងស-២៤ ។ គួរឲ្យកត់សម្គាល់ផងដែរថា ប្រតិចារឹកជាផ្លូវការរបស់ដំណើរការនីតិវិធីកាលពីម្សិលមិញនេះមិនទាន់មាននៅឡើយទេ ។ ដូច្នេះ ភាគីទាំងអស់ត្រូវតែបោះបង់ចោលការសំអាងដែលមិនមែនជាផ្លូវការ ។

យោងតាមកំណត់ត្រារបស់ខ្ញុំកាលពីម្សិលមិញ មេធាវីការពារក្តីនិយាយត្រូវ ។ ម្សិលមិញនេះ ជិន ម៉េត បាននិយាយថា រូបថតនេះត្រូវបានថតក្នុងឆ្នាំ១៩៧៧ ឬ១៩៧៨ ខណៈពេលដែលគាត់មានអាយុ១៩ឆ្នាំនៅមន្ទីរស-២៤កងពលលេខ១៧ ។ បន្ទាប់ពី ជិន ម៉េត បានរៀបរាប់ដូច្នេះ លោកប្រធានចៅក្រម និល ណុន បានមានយោបល់ថា ជិន ម៉េត មិនមានរូបរាងស្គមស្គាំងនៅក្នុងរូបថតទេ ។ ដូច្នេះលោកប្រធានបានសន្និដ្ឋានថា រូបថតនេះមិនមែនថតនៅមន្ទីរស-២៤ដូចដែល ជិន ម៉េត បានអះអាងថា នៅទីនោះគាត់ត្រូវបានបង្អត់អាហារនោះទេ ។

ដោយសារតែភាពច្របូកច្របល់ទាំងអស់នេះ ចៅក្រម ខាតរ៉ាយច៍ បានស្នើឲ្យ ឌុច ធ្វើការគូសបញ្ជាក់ថា តើ ឌុច ដឹងថារូបថតនេះថតនៅមន្ទីរស-២៤ដោយរបៀបណា ពីព្រោះ ឌុច បានអះអាងដូច្នេះយ៉ាងជឿជាក់កាលពីម្សិលមិញ ។ ឌុច បានអះអាងថា កាលពីម្សិលមិញគាត់បានយល់ស្របនឹងសក្ខីកម្មរបស់ ជិន ម៉េត ដោយសារតែ ជិន ម៉េត បាននិយាយយ៉ាងច្បាស់ថា រូបថតនេះមានប្រភពមកពីមន្ទីរស-២៤ ។ ឌុច បន្ថែមទៀតថា គាត់មិនបានធ្វើការពិនិត្យដោយខ្លួនឯងនោះទេ ។ យោងតាមកំណត់ត្រារបស់ខ្លួនកាលពីម្សិលមិញ ឌុច និយាយយ៉ាងច្បាស់ថា ព្រះរាជអាជ្ញាបានសួរ ឌុច ពីយោបល់របស់គាត់ទាក់ទិននឹងរូបថតពាក់កណ្តាលខ្លួនមួយសន្លឹកនេះ ដោយមូលហេតុថា ជិន ម៉េត មិនបានលេខកំណត់ចំណាំជាអ្នកទោស ។ ឌុច បញ្ជាក់យ៉ាងច្បាស់ថា រូបថតនេះថតនៅមន្ទីរស-២៤ ប៉ុន្តែវិវត្តន៍ទៅជាមន្ទីរស-២១ ។ ជាមួយគ្នានេះ ឌុច ក៏បានអះអាងថា ប្រវត្តិរូប ជិន ម៉េត ត្រូវបានរៀបរៀងដោយសមមិត្ត ហ៊ុយ នៅមន្ទីរស-២៤ បើទោះបីជារូបថតនេះត្រូវបានរក្សាទុកនៅមន្ទីរស-២១ក៏ដោយ ។

វាទំនងជាថា ជិន ម៉េត មានភាពច្របូកច្របល់កាលពីម្សិលមិញនេះ ហើយមិនបានគូសបញ្ជាក់ពីពេលវេលា និងទីកន្លែងដែលថតរូបនោះឲ្យបានច្បាស់ ។ ខ្ញុំមិនយល់ថាហេតុអ្វីបានជាមេធាវីរបស់ ជិន ម៉េត

មិននិយាយពីបញ្ហានេះ។ ថ្ងៃនេះ ជិន ម៉េត បានអះអាងថា រូបថតនេះត្រូវបានថតនៅកងពលទ័ព មុននឹងគាត់ត្រូវបានចាប់ខ្លួន ហើយស្របពេលជាមួយគ្នានេះប្រវត្តិរូបរបស់គាត់ក៏ត្រូវបានរៀបចំរួចជាស្រេចផងដែរ។ ចៅក្រមត្រូវតែធ្វើការសន្និដ្ឋានដោយខ្លួនឯង ពីព្រោះ ឌុច ក៏បានអះអាងថា រូបថតនិងប្រវត្តិរូប ជិន ម៉េត មានប្រភពពីមន្ទីរស-២៤ដែរ។ ដោយសារតែ ជិន ម៉េត ត្រូវបានចងភ្នែកនៅពេលចូលទៅដល់មន្ទីរឃុំឃាំង និងដោយសារតែគាត់មិនអាចរៀបរាប់ឲ្យបានលម្អិតនោះ រូបថតនិងប្រវត្តិរូបគឺជាភស្តុតាងតែមួយគត់ដែលអាចបញ្ជាក់ថា គាត់មានជាប់ពាក់ព័ន្ធនឹងមន្ទីរស-២១។

## ការវិវត្តន៍ទៅមុខនៃរឿងរ៉ាវ ជិន ម៉េត

កាលពីម្សិលមិញ ជិន ម៉េត បានផ្តល់នូវរឿងរ៉ាវដ៏លម្អិតមួយស្តីពីបទពិសោធន៍គាត់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យក្រោមការត្រួតពិនិត្យពីសំណាក់ចៅក្រម។ ប៉ុន្តែថ្ងៃនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មិនបានសួរសំណួរដែលអាចលាតត្រដាងពីរឿងរ៉ាវ ជិន ម៉េត ឲ្យកាន់តែច្រើននោះទេ។

ជាសង្ខេប ជិន ម៉េត ត្រូវបានបង្ខំឲ្យចូលរួមបំរើកងទ័ពនារីខ្មែរក្រហមរហូតដល់ពេលដែលគាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៧។ ជិន ម៉េត ត្រូវបានបញ្ជូនមកកាន់មន្ទីរឃុំឃាំង ដែលគាត់ជឿថា ជាមន្ទីរស-២១។ ក្នុងរយៈដប់ប្រាំថ្ងៃ គាត់បានជាប់ឃុំជាមួយនឹងនារីពីរនាក់ទៀត ដែលគាត់ស្គាល់ ប៉ុន្តែគាត់មិនបានឃើញអ្នកទោសផ្សេងទៀតឡើយ។ ជិន ម៉េត ត្រូវបានសួរចម្លើយ និងរងការធ្វើទារុណកម្ម ហើយក្រោយមកក៏ត្រូវបញ្ជូនមកកាន់កន្លែងឃុំឃាំងមួយទៀត ដែលគាត់ជឿថា ជាមន្ទីរស-២៤។ គាត់ត្រូវបានបង្ខំឲ្យធ្វើការក្នុងស្ថានភាពដ៏លំបាកនៅតាមវាលស្រែមុននឹងបញ្ជូនមកកងមួយទៀតដើម្បីដាំបន្លែ។ ជិន ម៉េត បានរត់ភៀសខ្លួនចេញពីទីកន្លែងនោះនៅពេលដែលកងទ័ពវៀតណាមបានមកដល់ ហើយចុងក្រោយបង្អស់ គាត់ក៏ត្រូវបានស្ត្រីចំណាស់ម្នាក់ទទួលយកទៅចិញ្ចឹម។

ដោយសារតែក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ជាទូទៅទទួលបានថេរវេលាត្រឹមតែសែសិបនាទី ថ្ងៃនេះ មេធាវីទាំងអស់ត្រូវបានប្រគល់អាទិភាពដល់ក្រុមអ្នកជំនួយផ្នែកច្បាប់ដែលជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីឲ្យឡើងមកធ្វើសក្ខីកម្ម។ ជិន ម៉េត ត្រូវបានតំណាងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ដូច្នេះមេធាវីក្រុមនេះនឹងប្រើប្រាស់រយៈពេលសែសិបនាទីនេះដើម្បីសួរសំណួរ។ ការធ្វើបែបនេះ គឺជាករណីលើកដំបូង។ បើទោះបីជាការប្រគល់ភារៈកិច្ចទាំងស្រុងទៅឲ្យក្រុមមេធាវីដែលមាន

ការដឹងយល់ច្រើនពីដើមបណ្តឹងរដ្ឋប្បវេណីនិងមានភស្តុតាងសំខាន់ៗ គឺជាការល្អក៏ដោយ ក៏ប៉ុន្តែលទ្ធផលដែលទទួលបាន គឺមានលក្ខណៈគួរឲ្យសោកស្តាយ ។

មេធាវីម្នាក់បានចំណាយពេលជិតដប់នាទី ដើម្បីសួរសំណួរទាក់ទិននឹងប្រវត្តិរូប ដើម្បីបង្កើតជាមូលដ្ឋានមួយដែលបញ្ជាក់ថា ជិន ម៉េត មិនបានចូលបំរើកងទ័ពខ្មែរក្រហមដោយស្ម័គ្រចិត្តទេ ។ នៅក្នុងអង្គជំនុំជម្រះដែលពេលវេលាមិនចោទជាបញ្ហានោះ ខ្ញុំអាចដឹងពីប្រយោជន៍នៃការចោទសួរសំណួរទាក់ទងនឹងប្រវត្តិរូប ដែលធ្វើឡើងក្នុងគោលបំណងបង្កើតជាភាពអាណិតអាសូរដល់ជនរងគ្រោះ និងទាញយកចម្លើយដែលពាក់ព័ន្ធគ្នា ។ យ៉ាងណាមិញ ពេលវេលាពិតជាមានសារសំខាន់ណាស់សម្រាប់អង្គជំនុំជម្រះនេះ ដូច្នេះសំណួរគួរតែផ្តោតទៅលើការបង្កើតជាករណីមួយ ។ វាមិនមានលក្ខណៈប្រាកដប្រជាទាល់តែសោះថា ជិន ម៉េត ពិតជាត្រូវបានជាប់ឃុំនៅមន្ទីរស-២១ ហើយពេលវេលាជាច្រើនត្រូវបានចំណាយគ្រាន់តែដើម្បីបញ្ជាក់ថា អស់រយៈពេលជាច្រើនឆ្នាំមុនពេលចាប់ខ្លួន ជិន ម៉េត បានរស់នៅជាមួយជីដូនជីតាគាត់ជាមួយនឹងភាពក្រីក្រតែប៉ុណ្ណោះ ។ លោកប្រធានចៅក្រម បានស្តីបន្ទោសឲ្យមេធាវីជាច្រើនដង ដោយបង្គាប់ឲ្យមេធាវីសួរសំណួរដែលពាក់ព័ន្ធនឹងភស្តុតាងសំខាន់ក្នុងការឃុំឃាំង ។ មេធាវីទីពីររបស់ក្រុមបីបានបន្តសួរ ឌុច នូវសំណួរដែលមិនជាប់ពាក់ព័ន្ធគ្នាចំនួនបួនក្នុងពេលតែមួយ ។ លោកប្រធានបានស្តីបន្ទោសឲ្យមេធាវីនោះដោយសួរថា តើ ឌុច អាចឆ្លើយតបនឹងសំណួរជាច្រើនក្នុងពេលតែមួយដែរឬទេ ។ ឌុច បានឆ្លើយតបនឹងសំណួរមួយ-ពីរ ប៉ុន្តែមិនអាចចងចាំសំណួរទាំងអស់នោះបានទេ ។ ឌុច ក៏បានស្តីបន្ទោសឲ្យមេធាវីដោយស្នើសុំថា គួរតែសួរសំណួរមួយក្នុងពេលតែមួយបានហើយ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីបានស្នើសុំពេលវេលាបន្ថែមសម្រាប់មេធាវីដទៃទៀត ប៉ុន្តែលោកប្រធានចៅក្រមបានជំទាស់ដោយគ្មានភាពស្ទាក់ស្ទើរឡើយ ។

ខណៈពេលដែលមានភាពមិនស៊ីគ្នារវាងសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរ ដែលប្រគល់ឲ្យតុលាការ និងការធ្វើសក្ខីកម្មដោយផ្ទាល់របស់ លី ហ៊ំ, ឡាយ ចាន់, និង ភោគ ខន ដែលបានធ្វើកាលពីសប្តាហ៍មុន ជិន ម៉េត បានសរសេរសេចក្តីសន្និដ្ឋានដោយខ្លួនឯង ហើយភាពមិនស៊ីគ្នារវាងសេចក្តីសន្និដ្ឋាន និងសក្ខីកម្មរបស់គាត់មានតិចតួចណាស់ ។ សេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀត ត្រូវបានរៀបរៀងដោយអង្គការមិនយកផលប្រយោជន៍ ហើយជាក់ស្តែងមិនសូវមានការត្រួតពិនិត្យឡើងវិញពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯងឡើយ ។ សំណួររបស់មេធាវីការពារក្តីទៅកាន់ ជិន ម៉េត ផ្តោត

ទៅលើភាពមិនស៊ីគ្នាតិចតួចទាំងនេះ និងការខ្វះខាតនូវឯកសារដែលបញ្ជាក់ថា ជិន ម៉េត ពិតជាត្រូវបានជាប់ឃុំឃាំងនៅមន្ទីរស-២១មែន ។

## អតីតគ្រូពេទ្យបានបាត់បង់សមាជិកគ្រួសារទាំងអស់នៅមន្ទីរស-២១

ក្នុងថ្ងៃនេះដើមបណ្តឹងរដ្ឋប្បវេណី ណាំ ម៉ុន អាយុ៤៨ឆ្នាំ បានឡើងមកធ្វើសក្ខីកម្មជំនួសឲ្យខ្លួនគាត់ និងជំនួសមុខឲ្យបងប្អូនប្រុសទាំងបួន ឪពុកម្តាយ និងពូពីរនាក់របស់គាត់ ដែលត្រូវបានសម្លាប់នៅមន្ទីរស-២១ ។

មុននឹង ណាំ ម៉ុន ចូលក្នុងបន្ទប់សវនាការដើម្បីធ្វើសក្ខីកម្ម មេធាវីរបស់គាត់ គឺ ស៊ីលឃី ស្ទូតហ្សិនស្គី បានក្រោកឈរជម្រាបចៅក្រមថា ព័ត៌មានថ្មីដែលត្រូវនឹងទាញយកបានពី ណាំ ម៉ុន ហើយ ណាំ ម៉ុន នឹងផ្តល់សក្ខីកម្មពីរឿងរ៉ាវដែលមានព័ត៌មានសំខាន់ៗជាច្រើន លើសពីអ្វីដែលបានរៀបរាប់នៅក្នុងសំណុំឯកសារស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីទៅទៀត ។ មេធាវី ស្ទូតហ្សិនស្គី បានលើកឡើងពីបញ្ហាដែល ណាំ ម៉ុន នឹងធ្វើការពិភាក្សា ហើយចៅក្រមនឹងស្តាប់នូវរឿងរ៉ាវនេះជាលើកដំបូង ។ ជាមួយគ្នានេះ មេធាវី ស្ទូតហ្សិនស្គី បានជម្រាបដល់ចៅក្រមថា ណាំ ម៉ុន មានសុខភាពទ្រុឌទ្រោមណាស់ អាចនឹងសុំពេលសម្រាកខ្លះ ។ លោកស្រីមេធាវីបានស្នើសុំកុំឲ្យចៅក្រមបង្គាប់ឲ្យ ណាំ ម៉ុន ធ្វើការគ្រប់គ្រងអារម្មណ៍ខ្លួនឯងហើយបានផ្តល់យោបល់ថា ទាំងចៅក្រម និងភាគីទាំងអស់គួរតែចាត់ទុកបញ្ហាសតិអារម្មណ៍របស់ ណាំ ម៉ុន ជា«ភស្តុតាងផ្លូវអារម្មណ៍» ។

បើទោះបីជាចៅក្រម ខាតរ៉ាយថ៍ តែងតែជាមនុស្សស្ងប់ស្ងាត់ក៏ដោយ ក៏ប៉ុន្តែពេលនេះវាបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ណាស់ថា លោកស្រីចៅក្រមមិនពេញចិត្តនឹងការថ្លែងរបស់មេធាវី ស្ទូតហ្សិនស្គី ឡើយ ។ លោកស្រីចៅក្រមបានសួរលោកស្រីមេធាវីថា តើលោកស្រីបានជួបជាមួយនឹង ណាំ ម៉ុន ប៉ុន្មានដង ហើយថ្ងៃណាខ្លះដែលលោកស្រីបានជួប ណាំ ម៉ុន ។ ក្រោយពីទទួលបានចម្លើយចំនួនពីរលើកមក ដែលម្តងធ្វើឡើងយូរណាស់មកហើយ និងម្តងទៀតទើបតែដប់ថ្ងៃមុននេះ ចៅក្រម ខាតរ៉ាយថ៍ បានសន្និដ្ឋានថា មេធាវី ស្ទូតហ្សិនស្គី មិនបានធ្វើការស៊ើបអង្កេតឲ្យបានពេញលេញពីរឿងរ៉ាវទាក់ទិននឹង ណាំ ម៉ុន ទេមុននឹងមកធ្វើការណែនាំចៅក្រម ។ ក្រោយពីថ្ងៃដ៏លំបាកកន្លងផុតទៅនៅថ្ងៃច័ន្ទ ចៅក្រម ខាតរ៉ាយថ៍ បានធ្វើការណែនាំប្រហាក់ប្រហែលគ្នានេះ ទៅកាន់ អាឡាំង វ៉ែនណឺ មេធាវី

ដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ដោយមានប្រសាសន៍ថា ចៅក្រមសង្ឃឹមទុកថាភាគីដើមបណ្តឹងរដ្ឋប្បវេណីបានរៀបចំខ្លួនឲ្យបានប្រសើរជាងនេះនាពេលអនាគត ។ ដោយធ្វើការឆ្លើយតបជាមួយនឹងបញ្ហាទីពីរដែលមេធាវី ស្ទូតហ្សិនស្គី បានលើកឡើងពីវិធីសាស្ត្រឲ្យចៅក្រមគួរតែណែនាំសាក្សីនោះ ចៅក្រមខាតរ៉ាយថ៍ បានពន្យល់ប្រាប់ថា ចៅក្រមទាំងអស់បានស្គាល់ស្ទើរពីភាពដែលអាចឡើងមកធ្វើសក្ខីកម្មបានរបស់សាក្សីរួចរាល់ហើយ ។ បន្ថែមលើនេះលោកស្រីចៅក្រមបានប្រាប់មេធាវី ស្ទូតហ្សិនស្គី ថាចៅក្រមទាំងអស់គឺសុទ្ធតែជា«ចៅក្រមដែលមានបទពិសោធន៍» ហើយចៅក្រមទាំងអស់នេះ មិនត្រូវការសេចក្តីណែនាំបែបនេះឡើយ ។

ឪពុកម្តាយរបស់ ណាំ ម៉ុន បានចូលរួមក្នុងចលនាប៉ះបោរកន្លងមក ដូច្នេះក្រោយពេលដែលប្រជាជនភ្នំពេញត្រូវបានជម្លៀស គ្រួសាររបស់ ណាំ ម៉ុន បានវិលត្រឡប់មកកាន់ទីក្រុងវិញដោយឪពុកគាត់បានបំរើការឲ្យផ្នែកគ្រប់គ្រងលើការថតចម្លងឯកសារសម្រាប់ខ្មែរក្រហម ។ ចំណែកឯបងប្រុសពីរនាក់របស់ ណាំ ម៉ុន បានរស់នៅមន្ទីរស-២១ដោយធ្វើការជាអ្នកយាម ។ ក្នុងពាក់កណ្តាលឆ្នាំ១៩៧៥ នៅពេលដែលគាត់ទើបតែមានអាយុ១៥ឆ្នាំ ណាំ ម៉ុន បានចាប់ផ្តើមធ្វើការជាគ្រូពេទ្យប្រចាំនៅមន្ទីរស-២១ ។ ណាំ ម៉ុន បានស្នាក់នៅក្នុងអគារមួយទល់មុខរបងច្រកចូលមន្ទីរស-២១ ជាមួយនឹងអ្នកគ្រូពេទ្យពីរនាក់ទៀត ។

ថៃដន្យមានថ្ងៃមួយក្នុងឆ្នាំ១៩៧៧ ណាំ ម៉ុន បានឃើញឪពុករបស់គាត់ ដែលជាប់ខ្នោះត្រូវបានអ្នកយាមបណ្តើរពីរថយន្តមួយចូលក្នុងបរិវេណមន្ទីរស-២១ ហើយត្រូវដោះសម្លៀកបំពាក់ចេញ ។ ឪពុក ណាំ ម៉ុន ជាប់ឃុំនៅក្នុងគុកមួយជាមួយនឹងកម្មាភិបាលខ្មែរក្រហមផ្សេងទៀត ។ ណាំ ម៉ុន ទៅសួរសុខទុក្ខឪពុកបានម្តង ហើយគាត់ឃើញថា ឪពុកគាត់បានទទួលរងនូវទារុណកម្មយ៉ាងធ្ងន់ធ្ងរ ។ ឪពុក ណាំ ម៉ុន បានប្រាប់ ណាំ ម៉ុន នៅឲ្យឆ្ងាយពីគាត់ ។ រយៈពេលប្រាំមួយខែក្រោយមក គ្រូពេទ្យម្នាក់បានប្រាប់ ណាំ ម៉ុន ថា បងប្រុស ណាំ ម៉ុន ម្នាក់ត្រូវបានចាត់តាំងឲ្យសម្លាប់ឪពុករបស់គាត់ ។ បីថ្ងៃក្រោយមក បងប្រុស ណាំ ម៉ុន ម្នាក់នោះ ត្រូវបានសម្លាប់ដោយមិនបានជាប់ឃុំឃាំងជាមុនឡើយ ។ បងប្រុស ណាំ ម៉ុន ត្រូវចោទថាជាខ្មាំង ក្រោយពីមានការស្ទាក់ស្ទើរមិនហ៊ានបាញ់សម្លាប់ឪពុក ។ ចំណែកឯបងប្រុសម្នាក់ទៀតរបស់ ណាំ ម៉ុន ដែលធ្វើជាអ្នកយាម រួមទាំងម្តាយ និងប្អូនប្រុសគាត់ត្រូវបានចាប់ខ្លួនភ្លាមៗផងដែរ ។ ណាំ ម៉ុន មិនដែលបានជួបមុខអ្នកទាំងនោះម្តងទៀតឡើយ ។

មួយខែក្រោយមក ណាំ ម៉ុន ត្រូវបានចាប់ខ្លួន ។ គាត់ត្រូវជាប់ឃុំនៅមន្ទីរស-២១ក្នុងរយៈពេលប្រមាណបីខែក្នុងបន្ទប់ឃុំឃាំងអ្នកទោសមួយក្នុងអគារដែលគាត់ធ្លាប់ថែទាំអ្នកទោស ។ ក្នុងអំឡុងពីរសប្ដាហ៍ដំបូង ណាំ ម៉ុន ត្រូវបានសួរចម្លើយ និងធ្វើទារុណកម្មពីរទៅបីដងក្នុងមួយថ្ងៃ ។ ណាំ ម៉ុន បានអះអាងថា គាត់គឺជាកូនស្រីរបស់ឪពុកម្ដាយធម៌ ហើយបានប្រើប្រាស់ឈ្មោះរបស់ឪពុកម្ដាយធម៌នោះជំនួសឲ្យឈ្មោះឪពុកម្ដាយបង្កើត ។ ថ្ងៃមួយនាពេលរសៀលបន្តិច ណាំ ម៉ុន ត្រូវបានដាក់ខ្នោះ និងនាំទៅកាន់រថយន្តមួយដែលដឹកគាត់ជាមួយនឹងអ្នកទោសប្រាំ ប្រាំមួយនាក់ផ្សេងទៀតទៅកាន់មន្ទីរស-២៤ ។ នៅមន្ទីរស-២៤ ណាំ ម៉ុន ក៏ត្រូវបានសួរចម្លើយ និងធ្វើទារុណកម្មដូចគ្នានឹងមន្ទីរស-២១ដែរ ។ ដោយមានការឃ្លាំមើលពីសំណាក់អ្នកយាមប្រដាប់ដោយកាំភ្លើង ណាំ ម៉ុន ត្រូវបានបង្ខំឲ្យជីករណ្ដៅធំៗដើមកប់សាកសពក្មេងដែលស្លាប់ ។ នាពេលយប់ ណាំ ម៉ុន ត្រូវបានជាប់ឃុំក្នុងបន្ទប់ឃុំឃាំងមួយដោយជើងរបស់គាត់ជាប់ខ្នោះ ។ ណាំ ម៉ុន បានធ្វើការនៅមន្ទីរស-២៤អស់រយៈពេលបីខែមុននឹងត្រូវបានបញ្ជូនទៅកាន់មន្ទីរឃុំឃាំងមួយទៀត រហូតដល់ពេលកងទ័ពវៀតណាមក្ដោបក្ដាប់ភ្នំពេញ ។

បើទោះបីជា ណាំ ម៉ុន មិនបានរកឃើញរូបថតរបស់គាត់ដែលថតនៅមន្ទីរស-២៤ក៏ដោយ ក៏គាត់បានជំនួសរូបថតគាត់ដោយរូបថតសមាជិកគ្រួសារគាត់ដែលថតនៅមន្ទីរស-២១ ។ ហើយទោះបីជា ណាំ ម៉ុន បានព្យាយាមធ្វើឲ្យខ្លួនគាត់មានភាពនឹងនរអស់រយៈពេលប៉ុន្មានម៉ោងកន្លងទៅនេះក៏ដោយ ក៏នៅពេលដែលលោកប្រធានចៅក្រម បានដាក់បង្ហាញរូបថតឪពុករបស់គាត់នៅលើកញ្ចក់កុំព្យូទ័រភ្លាម គាត់ក៏ចាប់ផ្ដើមយំយ៉ាងខ្លាំង ។ លោកប្រធានបានសម្រេចឲ្យសម្រាករយៈពេលដប់នាទីដើម្បីឲ្យ ណាំ ម៉ុន អាចសម្រួលអារម្មណ៍ ។ ជាថ្មីម្ដងទៀត លោកប្រធានបានដាក់បង្ហាញរូបថតឪពុក ណាំ ម៉ុន ហើយសួរថា តើ ណាំ ម៉ុន ស្គាល់មនុស្សនៅក្នុងរូបថតនេះទេ ។ ណាំ ម៉ុន ក៏ចាប់ផ្ដើមយំម្ដងទៀត ។ លោកប្រធានបានអញ្ជើញអង្គភាពអ្នកជំនាញគាំទ្រសាក្សីដើម្បីជួយ ណាំ ម៉ុន មុននឹងបញ្ឈប់ដំណើរការនីតិវិធីនៅក្នុងថ្ងៃនេះ ។

រឿងរ៉ាវដ៏មានឥទ្ធិពលរបស់ ណាំ ម៉ុន បានចាប់ផ្ដើមលាតត្រដាងម្ដងបន្តិចៗនៅក្នុងថ្ងៃនេះ ដូច្នេះចៅក្រមនឹងបន្តសួរសំណួរ ណាំ ម៉ុន នៅថ្ងៃច័ន្ទបន្តទៀត ។

## ថេរវេលា និង«ភាពស្មើគ្នានៃសមាសភាព»

បន្ថែមលើការពិនិត្យមើលសក្ខីកម្មរបស់ ណាំ ម៉ុន សាក្សីពីររូបទៀតនឹងត្រូវឡើងមកធ្វើសក្ខីកម្មនៅសប្តាហ៍ក្រោយដោយនឹងត្រូវធ្វើសក្ខីកម្មក្នុងរយៈពេលពីរថ្ងៃម្នាក់ ។ បើទោះបីជាឈ្មោះរបស់សាក្សីមិនត្រូវបានប្រកាសឲ្យដឹងយោងតាមវិធីសាស្ត្រការពារសាក្សីក៏ដោយ ក៏គេរំពឹងទុកថា អតីតបុគ្គលិកមន្ទីរ ស-២១ពីររូបនឹងឡើងមកធ្វើសក្ខីកម្ម ។

លោកប្រធានបានប្រកាសថា ការផ្តល់ថេរវេលាបច្ចុប្បន្ន គឺសម្រាប់ការសួរសាក្សីក្នុងរយៈពេលមួយថ្ងៃតែប៉ុណ្ណោះ ។ ដូច្នេះសម្រាប់ករណីសួរសាក្សីក្នុងរយៈពេលពីរថ្ងៃ លោកប្រធានបានប្រកាសបន្ថែមថេរវេលាជនដល់ភាគីទាំងអស់ដូចតទៅ ៖ ព្រះរាជអាជ្ញា៦០នាទី, មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងបីក្រុម៨០នាទី និងមេធាវីការពារក្តី៨០នាទី ។

មេធាវីការពារក្តីបានលើកឡើងពីបញ្ហា«ភាពស្មើគ្នានៃសមាសភាព» ដែលខ្លួនធ្លាប់បានលើកឡើងកាលពីមុន ។ មេធាវីការពារក្តីជឿថា ខ្លួនគួរតែទទួលបានថេរវេលាសរុបបញ្ចូលគ្នាពីភាគីព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ដូច្នេះ យោងតាមថេរវេលាខាងលើ មេធាវីការពារក្តីនឹងទទួលបានថេរវេលាចំនួន ១៨០នាទី ។ បើទោះបីជាមេធាវីអន្តរជាតិ ហ្វ្រង់ស្វ័រ រូ មិនមានវត្តមាននៅក្នុងថ្ងៃនេះក៏ដោយ ក៏លោកធ្លាប់បានរំឭកចៅក្រមថា ភាពមិនស្មើគ្នានៃការបែងចែកថេរវេលាអាចក្លាយជាប្រធានបទសម្រាប់បណ្តឹងឧទ្ធរណ៍នាថ្ងៃខាងមុខ ។